# លក្ខខណ្ឌផ្សេងៗនៃយុទ្ធនាការរបស់ Visa ដើម្បីគាំទ្រអាជីវករក្នុងស្រុក និងលើកទឹកចិត្តការប្រើប្រាស់ Tap ឬ ស្កេន ដើម្បីទូទាត់តាម Visa កាត

1. **ការណែនាំ៖** ឯកសារនេះបង្ហាញពីលក្ខខណ្ឌផ្សេងៗ ("លក្ខខណ្ឌ") សម្រាប់យុទ្ធនាការទីផ្សារ ("យុទ្ធនាការ") របស់ Visa Worldwide Pte. Ltd. ("Visa") ដែលមានគោលបំណងគាំទ្រដល់អាជីវករក្នុងស្រុកនិងលើកទឹកចិត្តអតិថិជនកាន់ Visa ក្នុងការប្រើប្រាស់ការទូទាត់ Tap ឬ **ស្កេនជាមួយ** Visa កាត។ យុទ្ធនាការនេះត្រូវបានរៀបចំ និងផ្តល់ជូនដោយក្រុមហ៊ុន Visa ដល់ម្ចាស់កាត Visa ដែលកាន់ប្រភេទប័ណ្ណឥណទាន **(Debit)** ប័ណ្ណឥណពន្ធ **(Credit)** ឬ ប័ណ្ណ **Pre-paid** ដែលមានសុពលភាព ("កាតមានសិទ្ធិ") ដែលចេញដោយស្ថាប័នផ្តល់ជូនដែលមានអាជ្ញាប័ណ្ណនៅក្នុងប្រទេសកម្ពុជា ("ម្ចាស់កាត", "អ្នក", "របស់អ្នក")។ យុទ្ធនាការនេះ មានសុពលភាពក្នុងរយៈពេលយុទ្ធនាការដូចបានកំណត់ខាងក្រោម និងអាស្រ័យលើសន្លឹកប័ណ្ណ (**Voucher**) មានក្នុងស្តុក (ដូចបានចែងជាលម្អិតនៅក្នុងមាត្រា ៤) ។ ដើម្បីជៀសវាងការយល់ច្រឡំ Visaកាតប្រភេទពាណិជ្ជកម្ម ឬកាតសម្រាប់អាជីវកម្ម នឹងមិនត្រូវបានរាប់បញ្ចូលជាកាតដែលមានសិទ្ធិទទួលបានសន្លឹកប័ណ្ណ និងមិនអាចទទួលផលប្រយោជន៍ណាមួយពីយុទ្ធនាការនេះឡើយ។
2. **បុគ្គលដែលអាចចូលរួមបាន៖**
    - ដើម្បីចូលរួមក្នុងយុទ្ធនាការនេះ អ្នកត្រូវតែជាម្ចាស់កាតមានសិទ្ធិ ដែលកាតនោះចេញដោយស្ថាប័នផ្តល់កាតដែលមានអាជ្ញាប័ណ្ណ (“ធនាគារសាមី”) ហើយប្រើប្រាស់ Tap ឬ ស្កេនដើម្បីទូទាត់ជាមួយVisaកាត ចំនួន 5ប្រតិបត្តិការ ឬ10 ប្រតិបត្តិការ ឬ15 ប្រតិបត្តិការក្នុងមួយខែ (ចំនុចលម្អិតមានចែងនៅក្នុងមាត្រា៥) នៅតាមបណ្តាហាងអាជីវកម្មខ្នាតតូចនិងមធ្យមនានាដែលចូលរួម។ សណ្លឹកប័ណ្ណផ្សេងៗគ្នានឹងត្រូវផ្តល់ជូនទៅតាមចំនួនប្រតិបត្តិការមានសិទ្ធិ ដូចមានចែងលម្អិតនៅក្នុងមាត្រា៤ខាងក្រោម។
    - “ហាងអាជីវកម្មខ្នាតតូចនិងមធ្យមដែលចូលរួម” រួមបញ្ចូល (ប៉ុន្តែមិនមានកំណត់ត្រឹម) ហាងអាជីវកម្មដែលសម្គាល់ដោយ MVV tag នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ Visa ហើយមានចំណូលពីការលក់ប្រចាំឆ្នាំតិចជាង (ចំពោះតែចំណូលដែលទូទាត់ជាមួយ**Visa**កាត) 60,000 ដុល្លារអាមេរិក។ ឧទាហរណ៍រួមមានតែមិនកំណត់ត្រឹម ហាងលក់ទំនិញតូចៗ ឬប្រភេទសេវាកម្មដែលផ្តល់ដោយអាជីវករក្នុងស្រុកដូចជា៖ តូបលក់ម្ហូបអាហារតូចៗ ហាងលក់សម្លៀកបំពាក់និងក្រណាត់ ហាងលក់វត្ថុអនុស្សាវរីយ៍ ហាងសិប្បកម្ម ហាងលក់គ្រឿងទេស និងសេវាដឹកជញ្ជូនក្នុងស្រុកដូចជា តុកតុក។  ហាងអាជីវកម្មខ្នាតតូចនិងមធ្យម សំដៅលើអាជីវកម្ម ឬបុគ្គលដែលមានកិច្ចសន្យាមានសុពលភាព ជាមួយស្ថាប័នដែលមានអាជ្ញាប័ណ្ណផ្តល់ដំណោះស្រាយទទួលការទូទាត់ជាមួយ

      **Visa**កាត **(acquirer).**

- ○ គ្រប់ប្រតិបត្តិការដែលមានសិទ្ធិប្តូរយកសន្លឹកប័ណ្ណ (**Voucher**) ត្រូវតែជាប្រតិបត្តិការដែលដំណើរការនៅលើប្រព័ន្ធ VisaNet (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ) ហើយនឹងរួមបញ្ចូលប្រតិបត្តិការដែលបានដំណើរការដោយធនាគារសាមីតាមរយៈប្រព័ន្ធ VisaNet ផងដែរ។
- ○ ការប្រគល់ទំនិញត្រឡប់ ការស្នើសុំសងប្រាក់វិញ ឬការលុបចោលប្រតិបត្តិការណាមួយក្រោមហេតុផលផ្សេងៗ ប្រតិបត្តិការទាំងនោះនឹងមិនត្រូវបានដាក់បញ្ចូលក្នុងយុទ្ធនាការនេះទៀតទេ ។

3. **រយៈពេលយុទ្ធនាការ**៖ យុទ្ធនាការនេះនឹងចាប់ផ្តើមពីថ្ងៃទី1 ខែធ្នូ ឆ្នាំ2025 រហូតដល់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2026 (រាប់បញ្ចូលទាំងថ្ងៃចាប់ផ្តើមនិងថ្ងៃបញ្ចប់) ឬរហូតដល់ថ្ងៃដែលសន្លឹកប័ណ្ណរង្វាន់អស់ពីស្តុក (“**រយៈពេលយុទ្ធនាការ**”)។
4. សន្លឹកប័ណ្ណរង្វាន់ (**Voucher**)៖ សន្លឹកប័ណ្ណ ដែលផ្តល់សម្រាប់យុទ្ធនាការនេះ (នីមួយៗហៅថា “**voucher**”) មានកំណត់ដូចខាងក្រោម៖
   - សម្រាប់ការបំពេញប្រតិបត្តិការចំនួន 5 ដងដំបូងក្នុងមួយខែ នឹងមានសិទ្ធិទទួលបានសន្លឹកប័ណ្ណសម្រាប់ភេសជ្ជៈមួយកែវ នៅហាងកាហ្វេ Brown។
   - សម្រាប់ការបំពេញប្រតិបត្តិការចំនួន5 ដងបន្ថែម (ឬប្រតិបត្តិការទី10) ក្នុងមួយខែ នឹងទទួលបានសន្លឹកប័ណ្ណ ១សន្លឹកបន្ថែមទៀតសម្រាប់ភេសជ្ជៈមួយកែវ នៅហាងកាហ្វេBrown។
   - សម្រាប់ការបំពេញប្រតិបត្តិការចំនួន 15 ដង ឬលើសពីនេះ ក្នុងមួយខែនឹងទទួលបានសន្លឹកប័ណ្ណមួយសម្រាប់ចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer ។

- ○ ម្ចាស់កាតត្រូវចំណាំថា “សន្លឹកប័ណ្ណ សម្រាប់ភេសជ្ជៈមួយកែវនៅហាងកាហ្វេ Brown” អាចទទួលបានអតិបរមា 2 សន្លឹកប័ណ្ណ ក្នុងមួយខែ និងអតិបរមា 12 សន្លឹកប័ណ្ណ ក្នុងរយៈពេលយុទ្ធនាការទាំងមូលសម្រាប់កាតមួយ។
- ○ ម្ចាស់កាតត្រូវចំណាំថា“សន្លឹកប័ណ្ណចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer” អាចទទួលបាន **1** សន្លឹកក្នុងមួយខែ និងអតិបរមា 6 សន្លឹកក្នុងរយៈពេលយុទ្ធនាការទាំងមូលសម្រាប់កាតមួយ។
- ○ ជារៀងរាល់ខែក្នុងអំឡុងពេលយុទ្ធនាការទាំងមូល សន្លឹកប័ណ្ណសម្រាប់ភេសជ្ជៈមួយកែវ នៅហាងកាហ្វេBrown ចំនួន **10,000** ប័ណ្ណ នឹងចែកជូនហើយអនុវត្តតាមគោលការណ៍ មកមុនបានមុន ចំពោះម្ចាស់កាតដែលបានអនុវត្តតាមជំហានណែនាំស្តីពីការទាញយកសន្លឹកប័ណ្ណ ដែលមានចែងនៅក្នុងមាត្រា**5**។
- ○ ជារៀងរាល់ខែក្នុងអំឡុងពេលយុទ្ធនាការទាំងមូល សន្លឹកប័ណ្ណចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer ចំនួន **150** នឹងចែកជូនហើយអនុវត្តតាមគោលការណ៍ មកមុនបានមុនចំពោះម្ចាស់កាតបានដែលអនុវត្តតាមជំហានណែនាំស្តីពីការទាញយកសន្លឹកប័ណ្ណ ដែលមានចែងនៅក្នុងមាត្រា**5**។

- សន្លឹកប័ណ្ណ មិនអាចផ្ទេរ មិនអាចប្តូរ និងមិនអាចសងប្រាក់វិញបានឡើយ។ សន្លឹកប័ណ្ណ នេះមិនអាចប្តូរយកសាច់ប្រាក់ ឬទំនិញផ្សេងបានទេ។ សុពលភាពនៃសន្លឹកប័ណ្ណនេះគិតចាប់ពីថ្ងៃដែលសន្លឹកប័ណ្ណចេញដោយសាមីដៃគូ រួមមានហាងកាហ្វេ Brown និង Cambodia Event Organizer ។

5. **ការទូទាត់ និងការប្រើ voucher ៖**
   - "សន្លឹកប័ណ្ណ សម្រាប់ភេសជ្ជៈមួយកែវ នៅហាងកាហ្វេ Brown"
     សន្លឹកប័ណ្ណ អាចប្រើសម្រាប់ប្តូរយកភេសជ្ជៈកែវតូចណាមួយចំពោះភេសជ្ជៈក្តៅ ឬត្រជាក់ (លើកលែងទឹកផ្លែឈើ) នៅហាងកាហ្វេ Brown ដែលមាននៅប្រទេសកម្ពុជា។ សន្លឹកប័ណ្ណនេះមានសុពលភាព 3 ខែ គិតចាប់ពីថ្ងៃដែលសន្លឹកប័ណ្ណចេញដោយសាមីដៃគូ ។ ប្រសិនបើ សន្លឹកប័ណ្ណ មិនត្រូវបានប្រើប្រាស់ក្នុងរយៈពេលនៃសុពលភាពរបស់វាទេ សន្លឹកប័ណ្ណ នឹងត្រូវផុតកំណត់។ សន្លឹកប័ណ្ណ ដែលបានផុតកំណត់ មិនអាចជំនួសថ្មីបានឡើយ។
   - "សន្លឹកប័ណ្ណសម្រាប់ចុះឈ្មោះចូលរួមទិវារត់ប្រណាំងដែលរៀបចំដោយ Cambodia Event Organizer"**។**

     សន្លឹកប័ណ្ណ ដែលមានកូដអាចប្រើសម្រាប់ចូលរួមឥតគិតថ្លៃ /ចុះឈ្មោះ សម្រាប់កម្មវិធី ឬកីឡារត់ប្រណាំងណាមួយដែលនៅមាននៅលើគេហទំព័រ Cambodia Event Organizer នៅខណៈពេលដែលប្រើសន្លឹកប័ណ្ណ ។
   - ម្ចាស់កាតអាចចូលទាញយក សន្លឹកប័ណ្ណ ដោយចុចលើ តំណភ្ជាប់ មាននៅលើគេហទំព័រយុទ្ធនាការ នៅក្នុងគេហទំព័ររបស់ក្រុមហ៊ុន **Visa**។ បន្ទាប់មក ម្ចាស់កាតនឹងត្រូវបានតភ្ជាប់ទៅកាន់គេហទំព័រ ("Website") ដែលតំរូវឲ្យបុគ្គលចូលរួមបញ្ចូល លេខ **Visa**កាត កាលបរិច្ឆេទផុតកំណត់របស់កាត លេខទូរស័ព្ទ ឬអ៊ីម៉ែល ដើម្បី**log in** និងពិនិត្យសន្លឹកប័ណ្ណ ដែលម្ចាស់កាតមានសិទ្ធទទួល និងចូលទាញយកមកប្រើប្រាស់បាន។
   - សម្រាប់សន្លឹកប័ណ្ណ នីមួយៗ យើងរក្សាទុកឲ្យរយៈពេល60ថ្ងៃ ដើម្បីអ្នកចូលរួមចូលមកយកសន្លឹកប័ណ្ណ ដែលរយៈពេល**60**ថ្ងៃរាប់ចាប់ពីថ្ងៃចុងក្រោយនៃខែនីមួយៗ។ ព័ត៌មានលម្អិតអំពី សន្លឹកប័ណ្ណ ម្ចាស់កាតអាចរកមើលបាននៅលើគេហទំព័រនៅពេលដែលទទួលបាន សន្លឹកប័ណ្ណ។
   - ប្រតិបត្តិការដែលមានសិទ្ធិទទួលបានសន្លឹកប័ណ្ណ សំដៅលើប្រតិបត្តិការទូទាត់បានជោគជ័យសម្រាប់គ្រប់ចំនួនទឹកប្រាក់ ដោយប្រើ Visa Tap **ដើម្បីទូទាត់** (Tap to Pay) ឬ **ស្កេន ដើម្បីទូទាត់** (Scan to Pay) នៅហាងអាជីវកម្មខ្នាតតូចនិងមធ្យមដែលចូលរួមក្នុងរយៈពេលមួយខែ។
   - ប្រសិនបើម្ចាស់កាតមិនបានទាញយក សន្លឹកប័ណ្ណ នៅក្នុងរយៈពេលកំណត់ទេ ម្ចាស់កាតនោះនឹងបាត់សិទ្ធិទទួលបាន សន្លឹកប័ណ្ណ នៅក្នុងខែដដែលនោះ។
   - ក្រុមហ៊ុន Visa ធនាគារសាមី និងអាជីវករនឹងមិនទទួលខុសត្រូវចំពោះ ការពន្យាពេលការបាត់បង់ ឬការខូចខាតក្នុងការផ្តល់ សន្លឹកប័ណ្ណ ក្នុងករណីការពន្យាពេល ការបាត់បង់ ឬការខូចខាតបង្កឡើង

ដោយហេតុផលណាមួយដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់ក្រុមហ៊ុន Visa ធនាគារសាមី និងអាជីវករ រួមមានប៉ុន្តែមិនកំណត់ត្រឹមករណីប្រធានសិក្ត ការខូចខាតប្រព័ន្ធគ្រប់គ្រង ឬការរំខានបណ្តាលមកពីសេវាកម្មរបស់ភាគីទីបី។ ក្នុងករណីដែលសន្លឹកប័ណ្ណមិនត្រូវអាចបញ្ជូនបាន ឬការផ្តល់ជូនត្រូវបានពន្យាពេលយ៉ាងខ្លាំងដោយសារហេតុដូចដែលបានលើកឡើង ក្រុមហ៊ុនVisa នឹងប្រើប្រាស់កិច្ចប្រឹងប្រែងដែលសមស្រប ដើម្បីផ្តល់សន្លឹកប័ណ្ណជំនួស ឬអត្ថប្រយោជន៍ផ្សេងដែលមានតម្លៃស្មើគ្នា។

6. **លក្ខខណ្ឌ និងគោលការណ៍ទូទៅ៖** ជាមួយការស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការនេះ អ្នក ៖
   - យល់ព្រមគោរពរាល់លក្ខខណ្ឌនានា និងសេចក្តីសម្រេចរបស់ Visa ទាក់ទងនឹងយុទ្ធនាការនេះ។
   - យល់ព្រមលើកលែងនិងការពារ Visa ធនាគារសាមី និងអាជីវករពីការទទួលខុសត្រូវចំពោះករណីណាមួយ អត្ថប្រយោជន៍ ការបាត់បង់ ខូចខាត ការចំណាយ ឬថ្លៃដើម ដែលកើតឡើង ឬទាក់ទងនឹងយុទ្ធនាការនេះ ឬ សន្លឹកប័ណ្ណ ។
   - ទទួលស្គាល់ថាការចូលរួមក្នុងកម្មវិធីនេះ គឺជាការចូលរួមដោយស្ម័គ្រចិត្តរបស់អ្នក ហើយមិនមែនជាកាតព្វកិច្ច ឬផ្លូវច្បាប់ណាមួយឡើយ។
   - ទទួលស្គាល់ថាក្រុមហ៊ុន Visa មានសិទ្ធិកែប្រែ ផ្អាក លុបចោល ឬបញ្ចប់យុទ្ធនាការនិងលក្ខខណ្ឌនានាឬមួយផ្នែកណាមួយដោយមានការជូនដំណឹងជាមុនទៅដល់ម្ចាស់កាត។
   - ទទួលថាក្រុមហ៊ុន Visa ជាអ្នកមានសិទ្ធិសម្រេចចុងក្រោយតែម្នាក់គត់ ក្នុងការកំណត់ប្រតិបត្តិការទូទាត់ដែលអាចរាប់បានថាជាប្រតិបត្តិការមានសិទ្ធិ ព្រមទាំងការទាញយកសន្លឹកប័ណ្ណ ហើយការសម្រេចចិត្តរបស់ Visa គឺជាសេចក្តីសម្រេចចុងក្រោយដែលត្រូវប្រតិបត្តិតាម ។
   - យល់ព្រមថា រាល់ពន្ធ ថ្លៃសេវា និងតម្លៃបន្ថែម ដែលកំណត់ដោយភាគីទីបីក្រៅពីក្រុមហ៊ុនVisa ទាក់ទងនឹងការទាញយក ឬប្រើប្រាស់សន្លឹកប័ណ្ណ (ឧទាហរណ៍ កម្រៃអ៊ីនធឺណេត កម្រៃបន្ថែម ឬកម្រៃដឹកជញ្ជូន) គឺជាការទទួលខុសត្រូវរបស់ម្ចាស់កាតផ្ទាល់ ។
   - យល់ព្រមថា ក្រុមហ៊ុនVisa នៅតែរក្សាសិទ្ធិក្នុងការបដិសេធ ឬដកសិទ្ធិអ្នកចូលរួមណាមួយ ដែលបានព្យាយាមបំភាន់ ឬជ្រៀតជ្រែកនឹងដំណើរការចុះឈ្មោះ ឬដែលបានដាក់ស្នើការចូលរួមដែលមិនគោរពតាមលក្ខខណ្ឌទាំងនេះ ឬមានសកម្មភាពណាមួយដែលរំខាន ឬព្យាយាមរំខានគោលបំណងនៃកម្មវិធីនេះ។
   - យល់ព្រមថា ក្រុមហ៊ុនVisa មិនទទួលខុសត្រូវចំពោះការបរាជ័យផ្នែកបច្ចេកទេស ដែលអាចរារាំងអ្នកណាម្នាក់ពីការចូលរួមក្នុងយុទ្ធនាការឡើយ។
   - យល់ព្រមថា នៅពេលសន្លឹកប័ណ្ណ ត្រូវបានប្រគល់រួចហើយ វាមិនត្រូវបានអនុញ្ញាតអោយលក់បន្ត ឬប្រើប្រាស់ជាផ្នែកពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលទេ។
   - យល់ព្រមគោរពតាមលក្ខខណ្ឌនានាដែលអនុវត្តចំពោះការចេញនិងការប្រើប្រាស់ សន្លឹកប័ណ្ណ ដូចដែលបានកំណត់ដោយ Brown និង Cambodia Event Organizer ។

- យល់ព្រមថា ក្រុមហ៊ុន Visa អាចផ្តល់ សន្លឹកប័ណ្ណជំនួស ឬអត្ថប្រយោជន៍ផ្សេងទៀតដែលមានតម្លៃស្មើគ្នាទៅតាមការសម្រេចរបស់ខ្លួន។
- យល់ព្រមថា ក្រុមហ៊ុន Visa ធនាគារសាមី ឬអាជីវករ មិនមានកាតព្វកិច្ច ឬការប្តេជ្ញាណាមួយក្នុងការធ្វើយុទ្ធនាការដូចនេះម្តងទៀត ឬយុទ្ធនាការផ្សេងទៀតនៅពេលក្រោយឡើយ។
- យល់ព្រមថា យុទ្ធនាការនេះ**នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើច្បាប់ហាម**ឃាត់។

7. **កម្រិតនៃការទទួលខុសត្រូវ៖**
    - ក្រុមហ៊ុន Visa ធនាគារសាមី និងអាជីវករ មិនទទួលខុសត្រូវចំពោះព័ត៌មានដែលខុស ឬមិនត្រឹមត្រូវ មិនថាបង្កឡើងដោយអ្នកចូលរួម ឬដោយឧបករណ៍ ឬកម្មវិធីណាមួយដែលពាក់ព័ន្ធនិង/ឬប្រើប្រាស់ក្នុងយុទ្ធនាការ។
    - ក្រុមហ៊ុន Visa ធនាគារសាមី និងអាជីវករមិនទទួលខុសត្រូវចំពោះ (១) បញ្ហារអាក់រអួល ឧបសគ្គការខកខាន ការលុប បញ្ហាទិន្នន័យ ការពន្យារពេលក្នុងប្រតិបត្តិការឬការផ្ទេរ បញ្ហាបណ្តាញទំនាក់ទំនង (២) ការលួច ឬការបំផ្លាញ ឬការចូលប្រើប្រាស់ដោយគ្មានអនុញ្ញាត ឬការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មាននានារបស់ម្ចាស់កាតដែលត្រូវបានបញ្ចូលទៅក្នុងវេបសាយ ឬ (៣) ភាពរអាក់រអួល **(error)** នៅក្នុងកំឡុងពេល **Log in** ឬ ក្នុងដំណើរការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកចូលរួម ដែលបណ្តាលមកពីអ្នកចូលរួមបំពេញពត៍មានមិនត្រឹមត្រូវ ខ្វះចន្លោះ និងមិនធ្វើតាមសេចក្តីណែនាំរបស់នីតិវិធីរបស់យុទ្ធនាការនេះ។
    - ក្រុមហ៊ុន Visa ធនាគារសាមី ឬអាជីវករមិនទទួលខុសត្រូវចំពោះបញ្ហា ឬកំហុសបច្ចេកទេសណាមួយ នៃបណ្តាញទូរស័ព្ទ ឬខ្សែទំនាក់ទំនង ប្រព័ន្ធអនឡាញកុំព្យូទ័រ ឬក្រុមហ៊ុនផ្គត់ផ្គង់ កម្មវិធី software ការបរាជ័យនៃអ៊ីម៉ែល ឬកម្មវិធី players ដែលបណ្តាលមកពីបញ្ហាបច្ចេកទេស ឬការរំខានក្នុងអ៊ីនធឺណេត ឬនៅលើគេហទំព័រណាមួយ ឬការរួមបញ្ចូលគ្នារបស់ពួកវា រួមទាំងការប៉ះពាល់ ឬខូចខាតដល់អ្នកចូលរួម ឬកុំព្យូទ័ររបស់អ្នកផ្សេងទៀត ដែលពាក់ព័ន្ធ ឬបណ្តាលមកពីការចូលរួម ឬទាញយកទិន្នន័យក្នុងយុទ្ធនាការ។
    - ក្រុមហ៊ុន Visa ធនាគារសាមី ឬអាជីវករនឹងមិនទទួលខុសត្រូវចំពោះសេវាកម្មដែលផ្តល់ដោយ Brown ឬ Cambodia Event Organizer ឬដៃគូផ្សេងទៀតដែលបានផ្តល់ដោយក្រុមហ៊ុន Visa និងចំពោះហេតុការណ៍ ឬបញ្ហាណាមួយដែលអាចកើតឡើងនៅពេលប្តូរយក voucher ឡើយ។

8. **ទិន្នន័យផ្ទាល់ខ្លួន៖**
    - ការចូលរួមក្នុងយុទ្ធនាការ អ្នកទទួលស្គាល់និងយល់ព្រមថា Visa និងភាគីទី៣ (ក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្មដែលប្រតិបត្តិការ) តំណាងអោយ Visa អាចប្រមូល ប្រើប្រាស់ ដំណើរការ និងចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកក្នុងគោលបំណង គ្រប់គ្រង និងចាត់ចែងយុទ្ធនាការ ("ទិន្នន័យផ្ទាល់ខ្លួន")។ ទិន្នន័យផ្ទាល់ខ្លួននេះរួមមានឈ្មោះ និងព័ត៌មានទំនាក់ទំនង ឬព័ត៌មានផ្ទាល់ខ្លួនចាំបាច់ណាមួយសម្រាប់រៀបចំរង្វាន់។ សម្រាប់ព័ត៌មានបន្ថែមពីវិធីដែល Visa ប្រមូលនិងការ

ការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក សូមចូលទៅកាន់ Global Privacy Notice (https://www.visa.com.kh/en_KH/legal/global-privacy-notice.html)។

- ប្រសិនបើអ្នកចង់អនុវត្តសិទ្ធិឯកជនណាមួយរបស់អ្នកតាមច្បាប់ដែលពាក់ព័ន្ធ សូមទំនាក់ទំនងមកកាន់ Visa Privacy Centre (https://www.visa.com.kh/en_KH/legal/privacy-policy.html).

9. **កម្មសិទ្ធិបញ្ញា៖** ការចូលរួមក្នុងយុទ្ធនាការ អ្នកទទួលស្គាល់ថា កម្មសិទ្ធិបញ្ញាណាដែលមាននៅលើយុទ្ធនាការ និងសម្ភារៈទាំងអស់ដែលប្រើប្រាស់ក្នុងការចូលរួមក្នុងយុទ្ធនាការនេះគឺជាកម្មសិទ្ធិរបស់ ឬត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ដោយក្រុមហ៊ុនVisa ហើយអ្នកមិនមានសិទ្ធិលើសម្ភារៈទាំងនេះទេ។
10. **ច្បាប់គ្រប់គ្រង៖** លក្ខខណ្ឌទាំងនេះត្រូវបានគ្រប់គ្រងដោយច្បាប់របស់ប្រទេសសឹង្ហបុរី ហើយរាល់ជម្លោះណាមួយដែលកើតឡើង ឬទាក់ទងនឹងលក្ខខណ្ឌទាំងនេះគឺស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការនៃប្រទេសសឹង្ហបុរី។
11. **កិច្ចព្រមព្រៀងទាំងស្រុង៖**
    - លក្ខខណ្ឌទាំងនេះបង្កើតបាននូវកិច្ចព្រមព្រៀងទាំងស្រុងរវាងអ្នកចូលរួមនីមួយៗ និង Visa ទាក់ទងនឹងយុទ្ធនាការ ហើយលុបបំបាត់រាល់ការរៀបចំ យោគយល់ ការចរចា និងការពិភាក្សាណាមួយដែលបានធ្វើមុននេះ មិនថាជាការនិយាយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខអក្សរ។
    - ការមិនអនុវត្ត ឬការលើកលែងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ មិនត្រូវបានគិតថាជាការលើកលែងលក្ខខណ្ឌផ្សេងទៀតឡើយ។
    - លក្ខខណ្ឌទាំងនេះត្រូវបានរៀបចំឡើងជាពីភាសា រួមមានភាសាអង់គ្លេស និងភាសាខ្មែរ។ ក្នុងករណីដែលមានភាពខុសឬផ្ទុយគ្នារវាងភាសាទាំងពីរ ភាសាខ្មែរត្រូវបានចាត់ទុកថាជាភាសាគោល។

សូមអានលក្ខខណ្ឌទាំងនេះដោយប្រុងប្រយ័ត្ន។ ប្រសិនបើអ្នកមិនយល់ព្រមលក្ខខណ្ឌទាំងអស់នេះ សូមកុំចូលរួមក្នុងយុទ្ធនាការនេះ។ ការចូលរួមក្នុងយុទ្ធនាការនេះ គឺបង្ហាញពីការយល់ព្រមរបស់អ្នកលើលក្ខខណ្ឌទាំងនេះ។ អ្នកនឹងត្រូវបានណែនាំឱ្យទទួលយកលក្ខខណ្ឌនៅលើគេហទំព័រ។

សម្រាប់សំណួរ ឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងទៅកាន់ផ្នែកសេវាកម្មបម្រើអតិថិជនរបស់ Razorpay តាមអ៊ីម៉ែល **Visaoffersupport@razorpay.com** ។ សូមចំណាំថា Visa និងធនាគារសាមីនឹងមិនទទួលខុសត្រូវចំពោះសេវាកម្មបម្រើអតិថិជនដែលពាក់ព័ន្ធនឹងយុទ្ធនាការនេះទេ។ ដើម្បីជៀសវាងការយល់ច្រឡំ ការទទួលខុសក្នុងការផ្តល់សេវាកម្មអតិថិជនពាក់ព័ន្ធនឹងយុទ្ធនាការនេះ ជាទំនួលខុសត្រូវរបស់ Razorpay តែមួយប៉ុណ្ណោះ។